**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ: ៧០៣៧ ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តបន្ទាយមានជ័យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តបន្ទាយមានជ័យជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**

និមិត្តសញ្ញាខេត្តបន្ទាយមានជ័យមានរាង ខ្នាត និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងពងក្រពើ
- មានទទឹងស្មើនឹង ២ ភាគ ៣ នៃបណ្ដោយ
- អមសងខាងក្នុងរង្វង់ដោយកួរស្រូវពណ៌លឿងទុំព័ទ្ធជាស្នែងក្របី រុំដោយបូដែលមានពណ៌ក្រហម និងផ្ទៃពណ៌ខៀវ
- នៅចំកណ្ដាលមានរូបចម្លាក់ព្រះអវលោកិតេស្វរៈដែលមានព្រះហស្ត៣២ ឈរលើកងចក្រ៧កាំ មានចារឹកអក្សរ "អវលោកិតេស្វរៈ" ពណ៌លឿង
- ផ្នែកខាងក្រោមមានបូពណ៌ខៀវលើ-ក្រោម និងចំកណ្ដាលផ្ទៃពណ៌ក្រហមមានអក្សរ "ខេត្តបន្ទាយ-មានជ័យ" ពណ៌ស
- អវលោកិតេស្វរៈ៖ ជាអ្នកជំក្នុងការប្រមើលមើល ឬពិនិត្យមើលសេចក្ដីសុខទុក្ខ និងចរិយារបស់សត្វលោក
- ព្រះហស្ត៣២៖ តំណាងឱ្យការកសាងព្រះបារមីរបស់ព្រះពោធិ៍សាត់ ដើម្បីសម្រេចបាននូវសម្មា-សម្ពោធិញ្ញាណ ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ
- កួរស្រូវពណ៌លឿងទុំ៖ តំណាងឱ្យផលិតផលកសិកម្ម ទទួលបានពីការប្រកបមុខរបរផ្អែកលើវិស័យកសិកម្ម ដោយប្រជាពលរដ្ឋខេត្តបន្ទាយមានជ័យចំនួនប្រមាណ៨៥%ជាប្រជាកសិករ
- កងចក្រមានកាំប្រាំពីរ៖ តំណាងឱ្យរោងចក្រ សហគ្រាសដែលជាសក្ដានុពលនាពេលបច្ចុប្បន្ន និងទៅអនាគត កើតមានឡើងក្នុងទឹកដីខេត្តបន្ទាយមានជ័យ ដែលផលិតផលកសិកម្មភាគច្រើនកើតឡើងពីដំណាំកសិឧស្សាហកម្ម ដូចជា ដំណាំដំឡូង ពោត សណ្ដែក ល្ហុងប្រេង ដើមប្រេងខ្យល់ និងកៅស៊ូ ។ល។ លក្ខណៈពិសេសមួយទៀត គឺតំណាងឱ្យថ្ងៃជ័យជំនះជាប្រវត្តិសាស្ត្រ ថ្ងៃ ៧មករា ១៩៧៩។

**ប្រការ ៣.-**

និមិត្តសញ្ញាខេត្តបន្ទាយមានជ័យត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការ-ដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ និងគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ០៥ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃការប្រកាសលេខ ២០៣៧ ប្រក**

**ចុះថ្ងៃ ចន្ទ ៨ រោច ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២**

**ត្រូវនឹងថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨**

**ស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តបន្ទាយមានជ័យ**

## និមិត្តសញ្ញាខេត្តបន្ទាយមានជ័យ